# ទស្សនៈ – ទិចារណកថា ផ្តល់ជូនកាសែតភ្នំពេញប៉ុស្តិ៍

## ការងារបំរើតាមផ្ទះ គឺជាការងាររបស់មនុស្សពេញវ័យ

### ដោយ ប៊ីល សលធី នាយក ការិយាល័យអនុតំបន់អាស៊ីបូព៌ានៃអង្គការអន្តរជាតិខាងការងារ

ខ្ញុំបានសួរខ្លួនឯងថាៈ តើមានស្ថានភាពបែបណាទៀតដែលធ្ងន់ធ្ងរជាងនេះ? តើនេះជាអំពើរំលោភបំពានលើកុមារដើម្បីចំណង់ផ្លូវភេទបែបពាណិជ្ជកម្មរបស់មនុស្សពេញវ័យឬជាភាពយង់ឃ្នងនៃទារុណកម្មដោយការវាយធ្វើបាបទៅលើកុមារ ក្នុងការបង្ខំឱ្យធ្វើការជាទាសករបំរើតាមផ្ទះ ?

បន្ទាប់ពីខ្ញុំបានអានប្រវត្តិក្មេងស្រីដ៏កំសត់អាយុ១១ឆ្នាំម្នាក់នេះ នៅក្នុងទំព័រកាសែតភ្នំពេញប៉ុស្តិ៍ដែលបានបោះពុម្ពផ្សាយកន្លងមក- ជាអ្នកបំរើតាមផ្ទះ - ជាអ្នកដែលគេរាយការណ៍ថា នាង ត្រូវបានគេជួញដូរទៅបំរើក្នុងគ្រួសារប្តីប្រពន្ធ រស់នៅក្នុងទីក្រុងភ្នំពេញ ហើយត្រូវបានគេធ្វើទារុណកម្មលើរាងកាយនាងមានទាំងការវាយដោយ រ៉ុំព័ទ្ធ-ខ្សែភ្លើង គាបសាច់នឹងដង្កាប់ដែក រហូតបាក់ឆ្អឹងឆ្អែង និង ដាច់រហែកសាច់បន្សល់ទុកនូវស្លាកស្នាមប្រហែលជា ២០០ កន្លែងនៅលើរាងកាយដ៏ក្មេងខ្ចីរបស់នាងកំសត់រូបនេះ ។

ខ្ញុំសូមគូសបញ្ជាក់យ៉ាងដូច្នេះ នៅពេលដែលនិយាយពីការរំលោភបំពានទៅលើកុមារ - ជាការពិតណាស់ស្ថានភាព ដែលយើងបានឃើញនេះ វាអាក្រក់ខ្លាំងណាស់ ហើយស្ថានភាពបែបនេះវាមិនមែនជាលើក ទី១ឡើយ ដែលខ្ញុំបានឃើញ នៅក្នុងរបាយការណ៏បែបនេះនៅក្នុងប្រទេសមួយចំនួនដូចជា កុមារីជាតិភូមាអាយុ១៧ឆ្នាំម្នាក់ស្ទើតែត្រូវបានសម្លាប់ដោយនិយោជករបស់នាងក្នុងទីក្រុងបាងកក និង កុមារីជនជាតិវៀតណាមម្នាក់ទៀត ត្រូវបានគេវាយធ្វើបាបជាប្រចាំ ដោយនិយោជកដែលជាម្ចាស់ផ្ទះ នៅទីក្រុងហាណូយ ។

មានសេចក្តីរាយការណ៏អះអាងបញ្ជាក់ថាការធ្វើទារុណកម្មលើកុមារីកម្ពុជារូបនេះមានរយៈពេលយ៉ាងតិចណាស់១ឆ្នាំមកហើយឬអាចវែងជាងនេះ - រហូតដល់អ្នកជិតខាងចូលធ្វើអន្តរាគមន៏ និងបានទាក់ទងទៅសមត្ថកិច្ចនគរបាលដើម្បីជួយសង្គ្រោះ ។ប្តីប្រពន្ធទាំងពីរនាក់ដែលជាមនុស្សប្រព្រឹត្តិអំពើឃោរឃៅលើរូបនាងតូចនោះនិងស្រ្តីចំណាស់ម្នាក់ទៀតដែលជាអ្នកនាំក្មេងស្រីទៅលក់ឱ្យប្តីប្រពន្ធទាំងពីរនាក់នោះត្រូវបានសមត្ថកិច្ចកម្ពុជា ឃាត់ខ្លួនជាបណ្តោះ អាសន្នដើម្បីតុលាការធ្វើការចោទប្រកាន់ពីបទថាបានលក់ក្មេងស្រី

ឱ្យធ្វើជាអ្នកបំរើតាមផ្ទះ និងប្រព្រឹត្តិអំពើទារុណកម្មលើរាងកាយ។ អ្នកទាំង៣នាក់បច្ចុប្បន្នកំពុងរង់ចាំការកាត់ក្តីទៅលើករណីជាច្រើនរួមមានទាំងបទជួញដូរមនុស្សផងដែរ ។

គួរឱ្យសោកស្តាយណាស់ដែលមានកុមារច្រើនណាស់កំពុងធ្វើជាឈ្នួលបំរើតាមផ្ទះនៅក្នុងទីក្រុងភ្នំពេញ ។ តាមការសិក្សាអង្កេតដែលគាំទ្រដោយអង្គការអន្តរជាតិខាងការងារ ក្នុងឆ្នាំ ២០០៣ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការបានរកឃើញថា មានកុមារបំរើតាមផ្ទះ ជិត ២៨០០០ នាក់នៅទីក្រុងភ្នំពេញតែមួយ ស្មើនឹង ១០ ភាគរយនៃកុមារទាំងអស់ដែលមាន អាយុពី ៧-១៧ឆ្នាំ ។

អង្គការអន្តរជាតិខាងការងារ បាននិងកំពុងធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកំពស់ការយល់ដឹងអំពីពលកម្មកុមារនិងផលប៉ះពាល់អវិជ្ជមានពីបញ្ហានេះដែលមានទៅលើសង្គមជាតិ ។តាមរយៈកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិខាងការងារមានលទ្ធភាព បង្ហាញថា ជាមួយនឹងអន្តរាគមន៍ត្រឹមត្រូវសមស្រប កុមារបំរើតាមផ្ទះអាចដកហូតចេញពីការងារ និង ស្តារនីតិសម្បទាឱ្យចូលទៅក្នុងសាលារៀនវិញបាន និងការទប់ស្កាត់មិនឱ្យមានកុមារបំរើតាមផ្ទះជាថ្មី ។ យើងកំពុងធ្វើការជាមួយគ្នា យ៉ាងជឿជាក់ឆ្ពោះទៅរកគោលដៅនៃប្រទេសគ្មានពលកម្មកុមារ នៅឆ្នាំ ២០១៦ ។ ភាពជឿនលឿនគួរឱ្យកត់សំគាល់កំពុងទទួលបានហើយស្ថានភាពកំពុងតែប្រសើរឡើង ។

កត្តាដែលយើងបានកត់សំគាល់ថាជាប្រការដ៏ល្អនោះគឺថាមានអ្នករស់នៅជិតខាងបានចូលមកជួយសង្គ្រោះកុមារី កាយវិការនេះជាសូចនាករបង្ហាញឱ្យឃើញថា សារប្រឆាំងពលកម្មកុមារកំពុងតែជ្រាបចូលក្នុងសមាជិកសង្គម ហើយ ប្រជាជនកម្ពុជា នឹងមិនបណ្តោយឱ្យអំពើរំលោភបំពានដោយផ្ទាល់ទៅលើ កុមារបែបនេះមានជាបន្តទៀតឡើយ ។

ប៉ុន្តែនៅមានកត្តាគួរឱ្យព្រួយបារម្ភមួយទៀតទាក់ទងនឹងប្រវត្តិរបស់កុមារីនេះ នោះគឺការរំលោភបំពានទៅលើកុមារបំរើតាមផ្ទះដែលមានលក្ខណៈជាប្រព័ន្ធជាទូទៅ។ ចរិតនៃការងារតាមផ្ទះមានការពាក់ព័ន្ធនឹងជាភាពដែលងាយរងគ្រោះ ព្រោះថាសកម្មភាពរបស់វាធ្វើនៅក្នុងទីកន្លែងបិទជិតស្ថិតនៅក្នុងផ្ទះរបស់

អ្នកដទៃ។ ក្នុងខណៈដែលកុមារីនេះមានវ័យក្មេងខ្ចីបំផុត ដែលមិនត្រូវទទួលយកឱ្យធ្វើការនៅទីណាមួយនោះអ្នកបំរើតាមផ្ទះគ្រប់វ័យទាំងអស់ជារឿយៗស្ថិតនៅក្នុងវិសមភាពក្នុងសង្គម (ដោយហេតុថាប្រព័ន្ធផ្សព្វផ្សាយមិនអាចចូលទៅដល់លំនៅដ្ឋានឯកជនបាន) ម្យ៉ាងទៀតនោះបញ្ហានេះ ត្រូវបានមើលរំលងដោយច្បាប់នៅនឹងកន្លែងធ្វើការងារ ការការពារសង្គមនៅមានភាពទន់ខ្សោយ ព្រមទាំងលក្ខខ័ណ្ឌការងារពុំមានលទ្ធភាពត្រួតពិនិត្យបាន ជាដើម ។ល។ និង ។ល។

ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានហេតុផលខ្លះសំរាប់សុទិដ្ឋិនិយមក្នុងចំណោមអ្នកធ្វើការបំរើតាមផ្ទះ ។ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនយ៉ាងច្បាស់លាស់អំពីការលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២ របស់អង្គការអន្តរជាតិខាងការងារ ស្តីពី ការលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និង បានរៀបចំផែនការជាតិស្តីពីការលុបបំបាត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ២០០៨ - ២០១២ ជាផែនការដែលអង្គការអន្តរជាតិខាងការងារកំពុងតែគាំទ្រ ។ ការងារបំរើតាមផ្ទះ ត្រូវបានគេកំណត់ថា ជាទំរង់នៃការងារមួយនៃទំរង់ការងារទាំង ១២ ប្រភេទ ដែលប្រកបដោយគ្រោះថ្នាក់ និងមិនអាចទទួលយកបាន ហើយកុមារត្រូវតែដកហូតចេញពីការងារប្រភេទ នេះជាបន្ទាន់ ។

កម្ពុជា ក៏បានផ្តល់សច្ចាប័នផងដែរលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារចំនួន ២ ទៀត ស្តីពីលុបបំបាត់ការងារដោយបង្ខំ ហើយកាលពីឆ្នាំកន្លងទៅ ច្បាប់ថ្មីប្រឆាំងការជួញដូរមនុស្ស ក៏បានចូលជាធរមាន រួចហើយដែរ ។

លើសពីនេះទៀត នៅថ្ងៃទី ២៧ ខែវិច្ឆិកា ខាងមុខនេះ រាជរដ្ឋាភិបាល នឹងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការងារសមស្របសំរាប់អ្នកធ្វើការងារបំរើតាមផ្ទះ - វាជាជំហាន ទី១ ដ៏សំខាន់ដែលនាំឱ្យមានការឈានទៅដល់ការបង្កើតឡើងស្តង់ដាអន្តរជាតិស្តីពីការពង្រីកកិច្ចការពារសង្គមដល់អ្នកដែលធ្វើការក្នុងផ្ទះរបស់អ្នកដទៃ ។

ការងារបំរើតាមផ្ទះ គឺជាការងារដ៏លំបាក ។ វាជាការងារជារឿយៗបំពេញដោយស្ត្រី និងជាការងារដែលផ្តល់សេរីភាពឱ្យសមាជិកនៃគ្រួសារនិយោជករបស់គាត់ អាចបន្តនិងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅផ្ទាល់របស់ពួកគេ ។ ប៉ុន្តែជារឿយៗ ទីកន្លែង និងអ្នកដែលធ្វើការនៅទីដែលបិទជិតទាំងនោះ ត្រូវបានគេទទួលស្គាល់ និងឱ្យតំលៃតិចតួចណាស់ ។ មានអ្នកធ្វើការងារបំរើតាមផ្ទះជាច្រើន ត្រូវបានគេរំលោភ បំពានទាំងលើរូបរាងកាយ និងផ្លូវភេទ ទាំងអារម្មណ៍និងផ្លូវចិត្តហើយបដិសេធសូម្បីតែសិទ្ធិជាមូលដ្ឋាន របស់មនុស្ស ។

នៅថ្ងៃទី ២៧ ខែវិច្ឆិកា នៅពេលដែលរាជរដ្ឋាភិបាល សមាគមនិយោជក សហជីព នឹងអង្គុយពិភាក្សាជុំគ្នាជាមួយអង្គការសង្គមស៊ីវិល លើប្រធានបទដ៏សំខាន់នេះ សូមទាំងអស់គ្នាចងចាំថាការងារបំរើតាមផ្ទះ គឺជាការងារពិតប្រាកដមួយ ។ វាជាការងារសំរាប់មនុស្សពេញវ័យដែលតម្រូវឱ្យមានសំណងសមស្រប មានពេលវេលាឈប់សំរាក មានសិទ្ធិក្នុងការធ្វើទំនាក់ទំនងជាមួយអ្នកដ៏ទៃ ជាងនេះទៀតត្រូវតែមានការធានាថា ការងារបំរើតាមផ្ទះ ជាការងារដែលត្រូវដំណើរការនៅក្នុងបរិស្ថានមួយមានសុវត្ថិភាព ។

នៅចុងបញ្ចប់នេះ ខ្ញុំសូមឱ្យយើងទាំងអស់គ្នាបញ្ជាក់ឡើងវិញថា ការងារនេះមិនមែនជាការងារសំរាប់ **ក្មេងៗ** ទេ ។